ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



អគ្គិសនីកម្ពុជា

លេខ : ០៦៤៥ សជណ.ធធក.ចប

# សេចក្តីជូនដំណឹង

## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើស**បុគ្គលិក ចំនួន ០៨រូប** ដើម្បីចូលបម្រើការងារនៅ តាមបណ្តាការិយាល័យ នាយកដ្ឋានអធិការកិច្ច នៃអគ្គិសនីកម្ពុជា ដូចខាងក្រោម :

* - **លក្ខណៈសម្បត្តិបេក្ខជន** :

**ក - ការិយាល័យអធិការកិច្ចអគ្គិសនីភ្នំពេញ** :

១ - បុគ្គលិកបច្ចេកទេសអធិការកិច្ចអគ្គិសនីភ្នំពេញ Comptage MV ចំនួន ០២ រូប

២ - បុគ្គលិកបច្ចេកទេសអធិការកិច្ចអគ្គិសនីទី១ Comptage LV ចំនួន ០១ រូប

៣ - បុគ្គលិកបច្ចេកទេសអធិការកិច្ចអគ្គិសនីទី២ Comptage LV ចំនួន ០១ រូប

៤ - បុគ្គលិកបច្ចេកទេសអធិការកិច្ចអគ្គិសនីទី៣ Comptage LV ចំនួន ០១ រូប

**- ការិយាល័យអធិការកិច្ចអគ្គិសនីខេត្ត** :

១ - បុគ្គលិកបច្ចេកទេសអធិការកិច្ចខេត្ត Comptage MV ចំនួន ០១ រូប

២ - បុគ្គលិកបច្ចេកទេសអធិការកិច្ចខេត្ត Comptage LV ចំនួន ០១ រូប :

- បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.II.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា វិស្វករអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Program AutoCAD

ខ - បុគ្គលិកបច្ចេកទេសស្រាវជ្រាវនិងចងក្រងឯកសារបទល្មើសអគ្គិសនី នៅ**ការិយាល័យអធិការកិច្ចរដ្ឋបាលទូទៅនិងស្រាវជ្រាវ-ចងក្រងឯកសារបទល្មើសអគ្គិសនី** ចំនួន ០១ រូប :

- បេក្ខជនទាំងពីរភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.II.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា បរិញ្ញាបត្រច្បាប់ ឡើងទៅ

*- **បញ្ជាក់** : ប្រសិនបើលទ្ធផលពិន្ទុប្រហាក់ប្រហែលគ្នា សម្រាប់បុគ្គលិកបច្ចេកទេសស្រាវជ្រាវនិងចងក្រងឯកសារបទល្មើសអគ្គិសនី គឺផ្តល់អទិភាពជូន ជនពិការ ។

*- **ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជាបេក្ខជនត្រូវទាញយក(Download) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅ អគ្គិសនីកម្ពុជា ។**

*- **បេក្ខជនត្រូវបំពេញពាក្យសុំចូលបម្រើការងារ និងត្រូវអញ្ជើញមកដាក់ពាក្យប្រឡងដោយផ្ទាល់ខ្លួន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ច្បាប់ដើមមកជាមួយ ។ ករណី បេក្ខជនមិនបានអញ្ជើញមកដាក់ពាក្យដោយផ្ទាល់ទេ អគ្គិសនីកម្ពុជា មិនទទួលពាក្យជូនឡើយ ។**

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់

- កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ ចំនួន ០១ ច្បាប់
- សលាកប័ត្របេក្ខជន ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ ចំនួន ០១ ច្បាប់
- តារាងពិន្ទុ (TRANSCRIPT) ចំនួន ០១ ច្បាប់
- ច្បាប់ដើម និងច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ចំនួន ០១ ច្បាប់

*- **ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធI នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។**

*- **ទីកន្លែងទទួលពាក្យ : នៅអគារ B ជាន់ទី១ ការិយាល័យបុគ្គលិក នៃអគ្គិសនីកម្ពុជា**
ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០ ។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

ថ្ងៃ អង្គារ ០៩ រោច ខែ ពុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៩

**ជ. រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកអគ្គិសនីកម្ពុជា**
**អគ្គនាយករង**

ELECTRICITE DU CAMBODGE

**អេង_គន្ធា**

**បញ្ជាក់**

- សេចក្តីជូនដំណឹងនេះ ធ្វើកាផ្សាយជាផ្លូវការ តាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ " ។